**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
*********

7: 1096
16-09-19

**នាមនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងរាជធានីភ្នំពេញ**

**សាលាដំបូងរាជធានីភ្នំពេញ**
*******

សាលក្រមព្រហ្មទណ្ឌលេខ: ៦២៦ "ក្រ២" វ
ចុះថ្ងៃទី ១៤.០៨.២០១៩
សំណុំរឿងព្រហ្មទណ្ឌលេខ: ៣៩៤
ចុះថ្ងៃទី ១៩-០១-២០១៩
សំណុំរឿងស៊ើបសួរលេខ: ២៤៥
ចុះថ្ងៃទី ២១-០១-២០១៩
ជំនុំជម្រះលេខ: ១២៦៤
ចុះថ្ងៃទី ១២-០៤-២០១៩

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅសាលាដំបូងរាជធានីភ្នំពេញ នាថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង ០៨ និង ០០ នាទីព្រឹក ដោយមានសមាសភាពចូលរួមដូចតទៅ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

-លោកស្រីចៅក្រម [redacted] ជាប្រធានក្រុមប្រឹក្សា
-លោកស្រីអនុប្រធាន [redacted] ជាចៅក្រមប្រឹក្សា
-លោកចៅក្រម [redacted] ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-កញ្ញា [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ៣៩៤ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ[redacted] ជ្រឹង ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើស្រែ ទីកន្លែងកំណើតនៅភូមិត្រពាំងខ្នារ ឃុំជិះរះពេន ស្រុកសំរោង ខេត្តតាកែវ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់[redacted] ខេត្តតាកែវ ឪពុកឈ្មោះ[redacted] "រ" ម្តាយឈ្មោះ[redacted]"រ" ប្រពន្ធឈ្មោះ[redacted] កូនគ្មាន ជាទីតិជន ទោសពីមុនគ្មាន។

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ: ៦២០ "អ" ជ.ឃ.ជ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៩។

-មានលោក[redacted]ម៉ានោ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted]ជ្រឹង ដែលមានការិយាល័យនៅផ្ទះលេខ ១១១អឺមួយ ផ្លូវលេខ២៩៨ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ។

២-ឈ្មោះ [redacted] សំបូរ ភេទប្រុស អាយុ៣៩ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើស្រែ ទីកន្លែងកំណើតនៅភូមិរមន់ ឃុំបឹងត្រាញ់ខាងជើង ស្រុកសំរោង ខេត្តតាកែវ ទីលំនៅមុនពេលឃាត់ខ្លួន[redacted] ស្រុកសំរោង ខេត្តតាកែវ ឪពុកឈ្មោះ[redacted] "រ" ម្តាយឈ្មោះ [redacted]"រ" ប្រពន្ធឈ្មោះ[redacted]រ" មានកូន០២នាក់ ជាទីតិជន ទោសពីមុនគ្មាន។

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ: ៦១៩ "អ" ជ.ឃ.ជ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៩។

-មានលោក [redacted] បូផា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted]សំបូរ ដែលមានការិយាល័យស្ថិតនៅផ្ទះលេខ២៤E0E1 ផ្លូវលេខ៤៩ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ/



Scanned with CamScanner

ខ្លួននិងឈ្មោះ [redacted] សំបូរ បានជិះម៉ូតូចេញពីតាកែវមកភ្នំពេញឈ្មោះ សំបូរ ជាអ្នកឌុបខ្លួន។ លុះមកដល់ផ្សារសេនជូរី ម្តុំពោធិ៍ចិនតុង ឈ្មោះ [redacted] សំបូរ បានចូលទៅយកថ្នាំញៀន ចំណែកខ្លួននៅចាំម៉ូតូខាងក្រៅ។ ឈ្មោះ [redacted] សំបូរ ក៏បានចេញមកវិញជាមួយឈ្មោះ រាម ហើយពេលនោះឈ្មោះ [redacted] ភាស់ បានទូរស័ព្ទមកខ្លួនឱ្យទៅយកលុយពីឈ្មោះ ហេង ចំនួន ៣០០$ ថ្លៃទំនិញថ្នាំញៀននៅម្តុំច្រមុះជ្រូកស្ទឹងមានជ័យ ឈ្មោះ [redacted] សំបូរ ឌុបខ្លួនទៅយក ពេលទៅដល់ខ្លួនចុះពីលើម៉ូតូដើរសំដៅទៅរកឈ្មោះ ហេង ក៏ត្រូវសមត្ថកិច្ចចាប់ឃាត់ខ្លួនតែម្តង។

-ជនជាប់ចោទឈ្មោះ [redacted] សំបូរ បានឆ្លើយនាពេលសវនាការថា: កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ ពេលល្ងាចមិនចាំម៉ោង ខ្លួនអង្គុយចាំឈ្មោះ [redacted] ជ្រឹង នៅលើម៉ូតូដោយឈ្មោះ [redacted] ជ្រឹង ប្រាប់ថាទៅទារលុយពីគេ ស្រាប់តែមួយសន្ទុះក្រោយមក ត្រូវសមត្ថកិច្ចឃាត់ពួកខ្លួនតែម្តង។ ខ្លួនស្គាល់ឈ្មោះ [redacted] ជ្រឹង ចំនួន០៤ខែហើយ សមត្ថកិច្ចបានដកហូតថ្នាំញៀននៅក្នុងកាបូបដែលឈ្មោះ រាម ផ្ញើនឹងខ្លួនយកទៅប្រគល់ឱ្យឈ្មោះ [redacted] ភាស់ ហើយនៅពេលសមត្ថកិច្ចឆែកឆេរឃើញថ្នាំញៀនចំនួន០១កញ្ចប់ នៅក្នុងកាបូបរបស់ខ្លួន។

-ក្រឡាបញ្ជីអានលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ១៧៣៦៥ មពអជបគញ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩ របស់មន្ទីរពិសោធន៍នៃអគ្គាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

-ក្រឡាបញ្ជីអានលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ១៧៥៥៥ មពអជបគញ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩ របស់មន្ទីរពិសោធន៍នៃអគ្គាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

-ក្រឡាបញ្ជីលើកំណត់ហេតុទទួលវត្ថុចាប់យក(២)លេខ ១៩៧ វវត ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានថា: ចំពោះរឿងនេះ ជនជាប់ចោទទាំងពីរនាក់ត្រូវបានចាប់ខ្លួនដោយសារវិធានបញ្ជ្រាបញ៉ង់។ ជាក់ស្តែងនៅថ្ងៃកើតហេតុ និងចាប់ខ្លួនជនជាប់ចោទទាំងពីរនាក់នោះគឺបានដកហូតថ្នាំញៀនបានចំនួន ៨៧,៦១ក្រាមពីឈ្មោះ [redacted] សំបូរ និងចំនួន ១០,១១ក្រាម ពីឈ្មោះ [redacted] ជ្រឹង និងសំភារៈមួយចំនួន។ បន្ទាប់មកសមត្ថកិច្ចបានយកចម្លើយរបស់ជនជាប់ចោទទាំងពីរនាក់ ហើយជនជាប់ចោទទាំងពីរនាក់ក៏បានឆ្លើយសារភាពថាពួកខ្លួនពិតជាបានមកភ្នំពេញដើម្បីទិញថ្នាំញៀនយកទៅឱ្យម៉ូយដែលបានកម៉ុងទិញព្រាកដអែន។ ប៉ុន្តែជាក់ស្តែង នៅពេលសវនាការនេះ ជនជាប់ចោទឈ្មោះ [redacted] ជ្រឹង នៅតែរក្សាចម្លើយរបស់ខ្លួនដដែល និងបានភ្ញាក់រលឹកដឹងពីកំហុសរបស់ខ្លួនដែលបានជាប់ពន្ធនាគារមួយរយៈនេះ ដូចនេះស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិនិត្យនិងពិចារណាពីស្ថានសម្រាលដល់ជនជាប់ចោទផង។ ដោយឡែកចំពោះឈ្មោះ [redacted] សំបូរ នាពេលសវនាការបានឆ្លើយបដិសេធទាំងស្រុងថា ខ្លួនពុំបានទាក់ទងទៅអ្នកផ្សេងដើម្បីទទួលទិញគ្រឿងញៀននោះទេ ប៉ុន្តែស្នើសុំឱ្យក្រុមប្រឹក្សាពិចារណាទៅលើចម្លើយជនជាប់ចោទនៅដំណាក់កាលរបស់សមត្ថកិច្ច។ ម្យ៉ាងទៀតជនជាប់ចោទជាប់ពន្ធនាគារមួយរយៈហើយ ពុំបានកែខ្លួននោះទេ ដូចនេះ ស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះពិចារណា និងពិនិត្យទៅភស្តុតាងក្នុងសំណុំរឿង និងតម្កល់ការចោទប្រកាន់ទៅលើជនជាប់ចោទទាំងពីរនាក់ដូចមាននៅក្នុងដីកាសន្និដ្ឋានស្ថាពរ និងស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចតាមច្បាប់។

-លោក [redacted] ម៉ានោ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ជ្រឹង បានធ្វើសេចក្តីសន្និដ្ឋានថា: នាពេលសវនាការនេះឃើញថា ចំពោះអង្គហេតុនេះគឺកូនក្តីខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាង/



Scanned with CamScanner

ជាប់ចោទពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចក្រោយស្ពានីយ៍ប្រេងសូគីមិច ច្រមុះជ្រូកស្ទឹងមានជ័យ មុខសាលាប៉ែលធី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## អង្គហេតុនៃរឿងមានដូចតទៅៈ

កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង១៦ និង២០នាទី សមត្ថកិច្ចការិយាល័យប្រឆាំងគ្រឿងញៀនខុសច្បាប់នៃមន្ទីរប្រឆាំងគ្រឿងញៀនបានអនុវត្តវិធានញុះញង់ឱ្យលក់គ្រឿងញៀនខុសច្បាប់នៅចំណុចក្រោយស្ថានីយ៍ប្រេងសូគីមិចច្រមុះជ្រូកស្ទឹងមានជ័យមុខសាលាប៉ែលធី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមាជ័យ រាជធានីភ្នំពេញ ឃាត់ខ្លួនជនសង្ស័យចំនួន២នាក់មានឈ្មោះ [redacted] ជ្រឹង ភេទប្រុស អាយុ៣២ឆ្នាំ និងឈ្មោះ [redacted] សំបូរ ភេទប្រុស អាយុ៣៩ឆ្នាំ ដែកឆែរឃើញក្រាមពណ៌សថ្លាចំនួន១កញ្ចប់(គេស្ព័បថមប្រភេទមេតំហ្វេតាមីន)ទម្ងន់ ១០,១១ក្រាម និងក្រាមពណ៌សថ្លាមួយកញ្ចប់ទៀត(គេស្ព័បថម ប្រភេទមេតំហ្វេតាមីន) ទម្ងន់ ៨៧,៦១ក្រាម ដាក់ក្នុងវ៉ាលីលើចង្កើម៉ូតូខាងមុខ។ មុនពេលកើតហេតុមានម៉ូយទំនាក់ទំនងទិញថ្នាំញៀនពីឈ្មោះ [redacted] ជ្រឹង និងឈ្មោះ [redacted] ភាស់។ បន្ទាប់មកឈ្មោះ [redacted] ជ្រឹង បានទំនាក់ទំនងយកថ្នាំញៀនពីឈ្មោះ [redacted] ភាស់ នៅចំណុចបន្ទប់ជួលរបស់ឈ្មោះ រាម ពេលទទួលថ្នាំញៀនរួចឈ្មោះ [redacted] ជ្រឹង និងឈ្មោះ [redacted] សំបូរ បានយកថ្នាំញៀនទៅប្រគល់ឱ្យម៉ូយ លុះពេលពួកគេកំពុងប្រគល់ថ្នាំញៀនឱ្យម៉ូយក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង រួចសមត្ថកិច្ចកសាងសំណុំរឿងរួមទាំងវត្ថុតាងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញចាត់ការតាមនីតិវិធី។

-បានឃើញៈ របាយការណ៍លេខ ១៧៧ រ.ប.ក ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៩ របស់មន្ទីរប្រឆាំងគ្រឿងញៀននៃអគ្គស្នងការដ្ឋាននគរបាលជាតិរាជធានីភ្នំពេញ។

-បានឃើញៈ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ២៥០ អ.យ.ខ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញៈ ដីកាសន្និដ្ឋានស្ថាពរលេខ ១១៣២ អ.យ.ខ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញៈ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១៥១៨ "អ" ជ.ជ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញៈ ដីកាសម្រេចលើកលែងចោទប្រកាន់លេខ ១៥១៧ "អ" ជជ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ជ្រឹង បានឆ្លើយនាពេលសវនាការថាៈ កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង០៩ និង០០នាទី ឈ្មោះ ហេង បានទូរស័ព្ទមកខ្លួនសួរថា មានថ្នាំញៀនដែរឬទេ។ ពេលនោះ ខ្លួនបានប្រាប់ថា អត់មានទេ ចាំខ្លួនសួរគេឱ្យ។ ប្រហែល១១ថ្ងៃត្រង់ ខ្លួនបានសួរទៅឈ្មោះ [redacted] សំបូរ ថាមានថ្នាំញៀនដែរឬទេ មានគេចង់ទិញ។ ឈ្មោះ [redacted] សំបូរ ថាអត់មានទេ ចាំទៅយកនៅភ្នំពេញ រហូតដល់ម៉ោង៤រសៀល//



Scanned with CamScanner

អយ្យការមែន ប៉ុន្តែការប្រព្រឹត្តរបស់គាត់គឺជាការជួញដូរលើកទីមួយ ដូចជាការបញ្ជាក់របស់កូនក្តីខ្លួនដែលថាថ្នាំញៀននេះគឺមានចំនួនតិច និងការរួសទាញពីមិត្តភក្តិ។ ហើយម្យ៉ាងទៀត ដោយសារមានជីវភាពខ្វះខាត ជាកម្មករសំណង់ចឹង ខ្វះការពិចារណាដោយសារគាត់រៀនអត់បានជ្រៅជ្រះ ហើយបើគិតពិចារណាឱ្យបានដិតដល់។ មួយទៀតកូនក្តីខ្លួនក៏បានបញ្ជាក់ផងដែរថា ទឹងកែប្រែកំហុសដូចដែលលោកតំណាងអយ្យការបានបញ្ជាក់ ដែលទាក់ទងនឹងគោលការណ៍គ្មានទោសដើម្បីឱ្យកូនក្តីខ្លួនកែប្រែកំហុស ប៉ុន្តែជាក់ស្តែងកូនក្តីខ្លួនបានដឹងកំហុសហើយ ដូចនេះស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះធ្វើការសម្រាលទោសដល់កូនក្តីខ្លួន។

-លោក [redacted] បូផា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សំបូរ បានធ្វើសេចក្តីសន្និដ្ឋានថា៖ ដោយយោងទៅលើការសាកសួរដោយផ្ទាល់របស់ក្រុមប្រឹក្សាជំនុំជម្រះ និងតំណាងអយ្យការ ឃើញថា ក្នុងពេលចុះប្រតិបត្តិការណ៍ សមត្ថកិច្ចបានប្រើវិធានញ៉ុះញង់ ដើម្បីចុះទៅដល់និងធ្វើការឃាត់ខ្លួនជនល្មើសពីបទល្មើស ជាក់ស្តែងប៉ុន្តែកូនក្តីខ្លួនបានបញ្ជាក់ថា បានធ្វើការឆែកឆេរចំនួនពីរដង ហើយវានៅតែមានចំណុចសង្ស័យ ដែលនៅពេលនោះកូនក្តីខ្លួនបានប្រគល់សំភារៈទៅឱ្យសមត្ថកិច្ចហើយ។ នៅពេលសួរដេញដោលនេះ ឈ្មោះ [redacted] ជ្រឹង បានឆ្លើយសារភាពថាខ្លួនពិតជាបានប្រព្រឹត្តអំពើជួញដូរមែន ចំណែកកូនក្តីខ្លួននៅតែឆ្លើយដដែល ទោះបីនៅក្នុងវ៉ាលីនោះមានថ្នាំញៀន ដែលថ្នាំញៀននោះគឺជារបស់ឈ្មោះ រាម ក៏ដោយ ប៉ុន្តែកូនក្តីខ្លួននៅតែឆ្លើយបដិសេធថាគាត់មិនបានប្រព្រឹត្ត ដែលមានភាពស៊ីសង្វាក់នៅពេលដែលបេជិះម៉ូតូមកនោះគឺពុំបានមិយាយគ្នាអ្វីនោះទេ។ ឈ្មោះ [redacted] ជ្រឹង បានទទួលកំហុសហើយ ប៉ុន្តែចំពោះកូនក្តីខ្លួនវិញគឺមិនបានពាក់ព័ន្ធជាមួយនឹងសំណុំរឿងនេះទេ។ ដូចនេះ ក្នុងនាមខ្លួនមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទមានសំណូមពរស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិចារណាត្រង់ចំណុចនេះ និងមេត្តាប្តូរបទចោទពីបទ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា ៤០ ទៅជាបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] សំបូរ ថា៖ ចំពោះរឿងនេះគឺខ្លួនស្នើសុំឱ្យតុលាការមេត្តាស្វែងរកយុត្តិធម៌ឱ្យខ្លួនផង ព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ។

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] ជ្រឹង ថា៖ ចំពោះរឿងនេះខ្លួនស្នើសុំឱ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្លួន។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ជ្រឹង និង [redacted] សំបូរ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើភស្តុតាងឯកសារផ្សេងៗនៅក្នុងសំណុំរឿង

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-តុលាការបានទទួលសំណុំរឿងព្រហ្មទណ្ឌលេខ ៣៩៤ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៩ មកជំនុំជម្រះតាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១៥១៨ “ររ” ដ.ដ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩ ដែលមាន

Scanned with CamScanner

ជនជាប់ចោទឈ្មោះ [redacted] ជ្រឹង ភេទប្រុស អាយុ៣២ឆ្នាំ និងឈ្មោះ [redacted] សំបូរ ភេទប្រុស អាយុ៣៥ឆ្នាំ ពីបទ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចក្រោយស្ថានីយ៍ប្រេងសូគីមិចច្រមុះជ្រូកស្ទឹងមានជ័យ មុខសាលាប៉ែលធី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង ១៦ និង ២០ នាទី សមត្ថកិច្ចការិយាល័យប្រឆាំងជំនួញគ្រឿងញៀនខុសច្បាប់នៃមន្ទីរប្រឆាំងគ្រឿងញៀនបានអនុវត្តវិធានញុះញង់ នៅចំណុចក្រោយស្ថានីយ៍ប្រេងសូគីមិចច្រមុះជ្រូកស្ទឹងមានជ័យ បានចាប់ឃាត់ខ្លួនជនត្រូវចោទ០២នាក់គឺ ឈ្មោះ [redacted] ជ្រឹង ភេទប្រុស និងឈ្មោះ [redacted] សំបូរ ភេទប្រុស ដោយឆែកឆេររកឃើញមានវត្ថុតាងក្រាមពណ៌សថ្លាចំនួន ១ កញ្ចប់ ដែលមានទម្ងន់ ១០,១១ក្រាម និងមួយកញ្ចប់ទៀតមានទម្ងន់ ៨៧,៦១ក្រាម នៅក្នុងវ៉ាលីលើចង្កើម៉ូតូខាងមុខ។

៣-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ជ្រឹង បានឆ្លើយថា នៅថ្ងៃកើតហេតុឈ្មោះ ហេង បានទូរស័ព្ទមកខ្លួនដើម្បីសួរនាំរកទិញថ្នាំញៀនតែខ្លួនថាអត់មានទេ ហើយក៏ខ្លួនថានឹងទាក់ទងទៅឈ្មោះ [redacted] សំបូរ ដើម្បីសួររកទិញថ្នាំញៀនបន្តដែរ។ ឈ្មោះ [redacted] សំបូរ ថាអត់ទេ តែចាំទៅយកថ្នាំញៀន ហើយនៅវេលាម៉ោង ៤ រសៀល ខ្លួននិងឈ្មោះ [redacted] សំបូរ បាននាំគ្នាជិះម៉ូតូមកភ្នំពេញទៅយកថ្នាំញៀននៅម្តុំពោធិ៍ចិនតុង ផ្សារសេនជ្វី ហើយនៅពេលនោះឈ្មោះ [redacted] ភាស់ បានទូរស័ព្ទមកខ្លួនឱ្យយកលុយចំនួន ៣០០$ពីឈ្មោះ ហេង ដើម្បីទិញថ្នាំញៀននៅម្តុំច្រមុះជ្រូកស្ទឹងមានជ័យ។

៤-ជនជាប់ចោទឈ្មោះ [redacted] សំបូរ បានឆ្លើយនៅពេលសវនាការថា កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ ពេលល្ងាចមិនចាំម៉ោង ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងអយ្យការនោះទេ។ ប៉ុន្តែចំពោះចម្លើយរបស់ជនជាប់ចោទគឺពុំមានភស្តុតាងណាមួយដោះបន្ទុកនោះទេ ជាក់ស្តែងនៅថ្ងៃកើតហេតុ ខ្លួនអង្គុយចាំឈ្មោះ [redacted] ជ្រឹង នៅលើម៉ូតូដោយឈ្មោះ [redacted] ជ្រឹង ប្រាប់ថាទៅទារលុយពីគេ ស្រាប់តែមួយសន្ទុះក្រោយមក ត្រូវសមត្ថកិច្ចឃាត់ពួកខ្លួនតែម្តង។ ខ្លួនស្គាល់ឈ្មោះ [redacted] ជ្រឹង ចំនួន០៤ខែហើយ សមត្ថកិច្ចបានដកហូតថ្នាំញៀនទៅក្នុងកាបូប ដែលឈ្មោះ រាម ផ្ញើនឹងខ្លួនយកទៅប្រគល់ឱ្យឈ្មោះ [redacted] ភាស់ ហើយនៅពេលសមត្ថកិច្ចឆែកឆេរឃើញថ្នាំញៀនចំនួន០១កញ្ចប់ នៅក្នុងកាបូបរបស់ខ្លួន។

៥-យោងតាមរបាយការណ៍លេខ ១៧៧ រ.បក ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៩ របស់មន្ទីរប្រឆាំងគ្រឿងញៀននៃអគ្គស្នងការដ្ឋាននគរបាលជាតិបញ្ជាក់ថា កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង ១៦ និង៣២នាទី នៅចំណុចក្រោយស្ថានីយ៍ប្រេងសូគីមិចច្រមុះជ្រូកស្ទឹងមានជ័យ មុខសាលាប៉ែលធី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ជនសង្ស័យឈ្មោះ [redacted] ជ្រឹង ភេទប្រុស អាយុ៣២ឆ្នាំ និងឈ្មោះ ផេង សំបូរ ភេទប្រុស អាយុ៣៥ឆ្នាំ ឈ្មោះ រាម ភេទប្រុស(គេចខ្លួន) និងឈ្មោះ [redacted] ភាស់ ភេទប្រុស (គេចខ្លួន) បានធ្វើសកម្មភាពជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន។

៦-តាមចម្លើយរបស់ជនជាប់ចោទ ក៏ដូចជារបាយការណ៍របស់សមត្ថកិច្ចគឺមានភាពស៊ីសង្វាក់ទៅនឹងភស្តុតាងនៅក្នុងសំណុំរឿងដែលបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] ជ្រឹង ភេទប្រុស និងឈ្មោះ [redacted] សំបូរ ភេទប្រុស ពិតជាបានទៅទិញគ្រឿងញៀនពីអ្នកដទៃដើម្បីយកទៅលក់បន្ត ហើយទទួលបានប្រាក់ចំណេញ ប្រាកដមែន។



Scanned with CamScanner

៧-តាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ១៧៣៦៥/១៩ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបង្ហាញថា សំណាកជាគ្រឿងញៀនប្រភេទក្រាម ម្សៅឈ្មោះ មេតំហ្វេតាមីន(ហៅក្រៅ អាយ ឬម៉ាទឹកកក) ដែលមានកម្រិតភាពសុទ្ធ ៧២,៩៥% (ចិតសិបពីរ ក្បៀស កៅសិបប្រាំភាគរយ) នៃទម្ងន់សរុបវាស្ថិតក្នុងតារាងទី២ មាត្រា ៥ ចំណាត់ថ្នាក់គ្រឿងញៀនដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៨-តាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ១៧៥៥៥/១៩ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបង្ហាញថា សំណាកជាគ្រឿងញៀនប្រភេទក្រាម ម្សៅឈ្មោះ មេតំហ្វេតាមីន(ហៅក្រៅ អាយ ឬម៉ាទឹកកក) ដែលមានកម្រិតភាពសុទ្ធ ៧៥,៥៣% (ចិតសិបប្រាំ ក្បៀស ហាសិបបី ភាគរយ) នៃទម្ងន់សរុបវាស្ថិតក្នុងតារាងទី២ មាត្រា ៥ ចំណាត់ថ្នាក់គ្រឿងញៀនដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៩-សារធាតុញៀនដែលចាប់យកពីជនជាប់ចោទឈ្មោះ [redacted] សំបូរ ជាក្រាមពណ៌សថ្លាមានទម្ងន់សរុបចំនួន ៨៧,៦១ ក្រាម ដែលជាសារធាតុមេតំហ្វេតាមីនមានកម្រិតភាពសុទ្ធចំនួន ៧៧,១៣% នៃទម្ងន់សរុប ដូចនេះបរិមាណសុទ្ធមេតំហ្វេតាមីនគឺ $\frac{72,95 \times 87,61}{100} = 63,911g$ ឃើញថាសារធាតុញៀនឈ្មោះ មេតំហ្វេតាមីន មានបរិមាណភាពសុទ្ធចំនួន ៦៣,៩១១ (ហុកសិបក្បៀស ប្រាំបួនរយដប់មួយ)ក្រាម ដូចនេះបរិមាណសុទ្ធចាប់ពី ១៥ (ក្រាម)រហូតដល់ ៨០(ប៉ែតសិប)ក្រាម ហើយដាក់ស្លាកសារធាតុដែលដកហូតពីឈ្មោះ [redacted] សំបូរ មានបរិមាណសុទ្ធ ៦៣,៩១១(ហុកសិបបី ក្បៀស ប្រាំបួនរយដប់មួយ) គឺស្ថិតនៅក្នុងមាត្រា ៤០ កថាខណ្ឌ៥ ចំណុច៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១០-សារធាតុញៀនដែលចាប់យកពីជនជាប់ចោទឈ្មោះ [redacted] ជ្រឹង ជាក្រាមពណ៌សថ្លាមានទម្ងន់សរុបចំនួន ១១,១១ ក្រាម ដែលជាសារធាតុមេតំហ្វេតាមីនមានកម្រិតភាពសុទ្ធចំនួន ៧៥,៥៣% នៃទម្ងន់សរុប ដូចនេះបរិមាណសុទ្ធមេតំហ្វេតាមីនគឺ $\frac{75,53 \times 10,11}{100} = 7,636g$ ឃើញថាសារធាតុញៀនឈ្មោះ មេតំហ្វេតាមីនមានបរិមាណភាពសុទ្ធចំនួន ៧,៦៣៦ (ប្រាំពីរក្បៀស ប្រាំមួយរយសាមសិបប្រាំមួយ)ក្រាម ដូចនេះបរិមាណសុទ្ធក្រោមពី ១៥ (ក្រាម) រហូតដល់ ៨០(ប៉ែតសិប)ក្រាម ហើយដាក់ស្លាកសារធាតុដែលដកហូតពីឈ្មោះ [redacted] ជ្រឹង មានបរិមាណសុទ្ធ ៧,៦៣៦ (ប្រាំពីរក្បៀស ប្រាំមួយរយសាមសិប) គឺស្ថិតនៅក្នុងមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១១-សកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] សំបូរ ភេទប្រុស និងឈ្មោះ [redacted] ជ្រឹង ភេទប្រុស ដែលបានយកថ្នាំញៀនពីអ្នកដទៃ ហើយយកទៅលក់បន្តដោយបានប្រាក់ចំណេញ ត្រូវបានច្បាប់កំណត់ថាជាបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ហើយបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៥ ចំណុច៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ និងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន)រៀល ទៅ ២០.០០០.០០០(ម្ភៃលាន)រៀល។

១២-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា: មានមូលដ្ឋានគ្រប់គ្រាន់ដើម្បីបញ្ជាក់ពីតម្រុយពិរុទ្ធភាពរបស់ជនជាប់ចោទ។

១៣-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានសន្និដ្ឋានថា: ស្នើសុំឱ្យកូនក្តីខ្លួនកែប្រែបទចោទពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន មកជាបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ការស្នើសុំនេះពុំមានមូលហេតុសមរម្យនោះទេដោយហេតុថា នៅពេលដែលសមត្ថកិច្ចចាប់ជាក់ស្តែងគឺមានថ្នាំញៀនច្រើន ដែលស៊ីសង្វាក់ទៅនឹងចម្លើយជនជាប់ចោទឈ្មោះ [redacted] ជ្រឹង បញ្ជាក់ថាមកទិញថ្នាំញៀនជាមួយគ្នាដើម្បីយកទៅឱ្យគេ។

១៤- មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] សំបូរ ភេទប្រុស អាយុ៣៩ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] ជ្រឹង ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែរ ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចក្រោយស្តាទីយ៍ប្រេងស្វូគីបិចច្រមុះជ្រូកស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១៥-យោងតាមកំណត់ហេតុទទួលវត្ថុតាងចាប់យក(២)លេខ: ១៩៧ រ.វ.ត ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញជាវត្ថុតាងដែលពាក់ព័ន្ធនឹងបទល្មើស គប្បីសម្រេចរឹបអូសតាមមាត្រា ៦២ និងមាត្រា៦៣ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន គឺ ១-ស្រោមសំបុត្របិតទជិតពណ៌លឿងដែលមានសរសេរថា ប្រភេទម្សៅក្រាមសថ្លាទម្ងន់ ៨៧,៦១ក្រាម មានស្នាមមេដៃឈ្មោះ ផេង សំបូរ, ២-ស្រោមសំបុត្របិតជិតពណ៌លឿនដែលមានសរសេរថា ប្រភេទម្សៅក្រាមសថ្លាទម្ងន់ ១០,១១ក្រាម ដោយមានស្នាមផ្តិតមេដៃរបស់ជនសង្ស័យឈ្មោះ [redacted] ជ្រឹង និងចូលរួមចុះហត្ថលេខាពីមន្ត្រីនគរបាលយុត្តិធម៌ និង៣-ទូរស័ព្ទដៃចំនួន០១គ្រឿង(មិនដំណើរការ)។

១៦-យោងតាមកំណត់ហេតុចាប់យក សំភារ: ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៩ នៅអំណាក់កាលរបស់សមត្ថកិច្ច បានបញ្ជាក់ថា ចំពោះវត្ថុតាងម៉ូតូម៉ាកហុងដាឌ្រីម ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1HD-៨១៨៦ លេខតួនិងលេខម៉ាស៊ីន ND125M5309112 ចំនួន០១គ្រឿង ដែលដកហូតពីឈ្មោះ [redacted] សំបូរ គឺជាវត្ថុតាងដែលពាក់ព័ន្ធនឹងបទល្មើស គប្បីរឹបអូសតាមមាត្រា ៦២ និងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ។

## ហេតុដូច្នេះ សម្រេច

១-ផ្តន្ទាទោស៖

ក-ឈ្មោះ [redacted] ជ្រឹង ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើស្រែ ទីកន្លែងកំណើតនៅភូមិត្រពាំងខ្វារ ឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់ [redacted] ខេត្តតាកែវ ឪពុកឈ្មោះ [redacted] “រ” ម្តាយឈ្មោះ ប៉េង ថា “រ” ប្រពន្ធឈ្មោះ [redacted] កូនគ្មាន ជាទីតិជន ទោសពីមុនគ្មាន។

ដាក់ពន្ធនាគារកំណត់ ០៨(ប្រាំបី)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០.០០០.០០០(ដប់លាន)រៀល។

ខ-ឈ្មោះ [redacted] សំបូរ ភេទប្រុស អាយុ៣៩ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើស្រែ ទីកន្លែងកំណើតនៅភូមិរមង់ ឃុំបឹងត្រាញ់ខាងជើង ស្រុកសំរោង ខេត្តតាកែវ ទីលំនៅមុនពេលឃាត់ខ្លួន [redacted] ស្រុកសំរោង ខេត្តតាកែវ ឪពុកឈ្មោះ [redacted] “រ” ម្តាយឈ្មោះ [redacted] “រ” ប្រពន្ធឈ្មោះ [redacted] “រ” មានកូន០២នាក់ ជាទីតិជន ទោសពីមុនគ្មាន។

ដាក់ពន្ធនាគារកំណត់ ០៨(ប្រាំបី)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០.០០០.០០០(ដប់លាន)រៀល។

ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចក្រោយស្ពានទីយ៍ប្រេងសូគីមិចច្រមុះជ្រូក ស្ទឹងមានជ័យ មុខសាលាប៊ែលធី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-រឹបអូសវត្ថុតាងមាន ថ្នាំញៀនប្រភេទម្សៅក្រាមសផ្លាទម្ងន់ទាំងអស់សរុប ៩៧,៧២ (កៅសិបប្រាំពីរ ក្បៀស ចិតសិបពីរ)ក្រាម និង ម៉ូតូម៉ាកហុងដាឌ្រីម ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ ១HD-៨១៨៦ លេខតួនិងលេខម៉ាស៊ីន ND125M5309112 ចំនួន០១គ្រឿង។

-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ និងប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ជ្រឹង និងឈ្មោះ [redacted] ប៉ុប្ល។ ទុកបើកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។/

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា |
| [redacted] | [redacted] | [redacted] | [redacted] |

---

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃស្រុក ៨រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩
ក្រឡាបញ្ជី

[redacted]

Scanned with CamScanner